**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុ

ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក
ថ្ងៃទី១៥ខែមេសាឆ្នាំ២០២០វេលាម៉ោង១៣:០០រសៀលនៅក្រុមហ៊ុនអាយវីចហ្វេកធើរី
(ខេមបូឌា)ឯ.ក

អាសយដ្ឋាន៖ ផ្លូវជាតិលេខ៤ភូមិត្រពាំងក្រសាំងឃុំបែកចានស្រុកអង្គស្នួលខេត្តកណ្ដាល ក្រោមអធិបតីភាពលោកស្រី He Shi Juan ជាជំនួយការនាយក និងលោក ដួងសារិន ជាប្រធានរដ្ឋបាលបាន ពិនិត្យអំពីបញ្ហាក្រុមហ៊ុនជួបវិបត្តិ គ្មានអ្វៀវបញ្ជាទិញដោយសាជំងឺរលាកផ្លូវ ដង្ហើមធ្ងន់ធ្ងរ COVID-19 ដូច្នេះហើយទើបក្រុមហ៊ុនឈានទៅដល់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៧៩នាក់ ស្រី៥០នាក់ ប្រុស២៩នាក់។

សមាសភាពចូលរួម

-តំណាងនិយោជក

- He Shi Juan ជាជំនួយការនាយក
- ដួង សារិន ជាប្រធានរដ្ឋបាល

-តំណាងកម្មករនិយោជិត

- កញ្ញា ចាន់ធួនស្រីនាត ប្រធាន សហជីពកម្មករអាស៊ានក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក
- លោក គឹម ពិសី អនុប្រធានសហជីពកម្មករអាស៊ានក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក
- កញ្ញា ញឹមស្រីតូច លេខាធិការសហជីពកម្មករអាស៊ានក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក

កញ្ញា ចាន់ធួនស្រីនាត ប្រធាន សហជីពកម្មករអាស៊ានក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក មានប្រសាសន៍ថា ក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន ព្រោះគ្មានអ្នកបញ្ជាទិញដោយសារជំងឺ COVID-19 ដូច្នេះខ្ញុំមិនជំទាស់ការព្យួរការងារនេះទេ។

លោក កែវសុភោគ ជាតំណាងកម្មករ ក្រុមហ៊ុនអាយវីចហ្វេកធើរី(ខេមបូឌា)ឯ.ក មានប្រសាសន៍ថា ខ្ញុំឯកភាពលើការព្យួរការងារនេះព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន។

ប្រធានគ្រប់គ្រងផ្នែកទាំងអស់បានចូលរួមកិច្ចប្រជុំ ហើយបានឯកភាពទាំងអស់គ្នារួចផ្តិតមេដៃជាភស្តុតាង។

-លទ្ធផលពិភាក្សា

- លោកស្រី He Shi Juan ជាជំនួយការនាយកក្រុមហ៊ុន និងតំណាងកម្មករ ហើយប្រធានសហជីពមូលដ្ឋានបានឯកភាពគ្នាលើការព្យួរកិច្ចសន្យាការងារនេះព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថាដោយសារតែក្រុមហ៊ុនយើងខ្ញុំគ្មានអ្នកបញ្ជាទិញដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនទាំងមូលដំណើរការបានហេតុដូច្នេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់រយៈពេលចំនួន១ខែគឺចាប់ពី ថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ ប្រាក់ឈ្នួលចំនួន៣០ ដុល្លាក្នុងមួយខែសម្រាប់កម្មករនិយោជិតម្នាក់ៗ។

-កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង១៤:៣០នាទីរសៀលធ្វើនៅថ្ងៃខែឆ្នាំដដែល។

ខេត្តកណ្តាលថ្ងៃទី១៥ខែមេសាឆ្នាំ២០២០

តំណាងកម្មករនិយោជិត និង សហជីពកម្មករអាស៊ាន        ហត្ថលេខានាយកក្រុមហ៊ុន

ចាន់ធួនស្រីនាត    កែវសុភោគ    គីមពិសី

ញឹមស្រីតូច    សុំហាក់    យាងទៀង

លុយបូលីតា    ទន់ពៅ